# <u>សុន្ទរកថា</u>

## ឯកឧត្តម ថាច់ សេដ្ឋា សមាជិកព្រឹទ្ធសភា
## និងជានាយកប្រតិបត្តិសហាគមន៍ខ្មែរកម្ពុជាក្រោម ក្នុងទិវាកាន់ទុក្ខជាតិខ្មែរ
## ខួបគម្រប់ ៦៣ឆ្នាំ ថ្ងៃអាណានិគមបារាំងកាត់ទឹកដីខ្មែរឲ្យវៀតណាម
## និងពិធីបុណ្យរាប់បាត្រព្រះសង្ឃ ១៩៤៩អង្គ នៅរាជធានីភ្នំពេញ
## ០៤-៦-១៩៤៩ - ០៤-៦-២០១២

សូមនមស្ការចំពោះប្រជុំបីនៃព្រះត្រៃរតន៍!

សូមគោរពនិងក្រាបថ្វាយបង្គំព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវីរព្រះមហាក្សត្រ វិញ្ញាណក្ខន្ធវីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារីខ្មែរស្នេហាជាតិទាំងអស់ដ៏ខ្ពង់ខ្ពស់បំផុត!

សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ!

សូមថ្វាយបង្គំ*សម្តេច ស៊ីសុវត្ថិ ពង្សនារី មុនីពង្ស* ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ នៃ*ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី* ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាព្រះអធិបតីដ៏ខ្ពង់ខ្ពស់!

សូមគោរព សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ជាទីគោរពស្នេហា!

តាងនាមព្រះសង្ឃ ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម និងក្នុងនាមទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតថ្លែងនូវអំណរព្រះមហាទិគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ថ្វាយ*ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី* ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលបានសព្វព្រះទ័យប្រោសព្រះរាជទាន*សម្តេច ស៊ីសុវត្ថិ ពង្សនារី មុនីពង្ស* ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ ធ្វើជាព្រះអធិបតីក្នុងពិធីបុណ្យជាប្រវត្តិសាស្ត្រនាពេលនេះ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតថ្លែងនូវកតញ្ញូតាធម៌និងថ្លែងនូវអំណរព្រះមហាករុណាទិគុណជាភយ្យោភាពថ្វាយ*ព្រះករុណាព្រះមហាវីរក្សត្រ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ* និង*សម្តេចព្រះមហាក្សត្រីយ៍* ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ដែលតែងតែលើកទឹកចិត្ត និងប្រោសព្រះរាជទាននូវការឧបត្ថម្ភគាំទ្រដល់គ្រប់សកម្មភាពតស៊ូស្របច្បាប់របស់ព្រះសង្ឃ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមជានិច្ច។ ជាពិសេស បានប្រោសព្រះរាជទាននូវព្រះរាជទ្រព្យផ្ទាល់ចំនួន ២០០០ដុល្លារសហរដ្ឋអាមេរិក ដើម្បីរៀបចំពិធីបុណ្យនេះជារៀងរាល់ឆ្នាំមិនដែលខកខានម្តងណាឡើយ។ នេះជាការបង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីទឹកព្រះទ័យប្រកបដោយព្រហ្មវិហារធម៌នៃព្រះមហាក្សត្រខ្មែរចំពោះព្រះសង្ឃ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមយ៉ាងពិតប្រាកដ។

ក្នុងឱកាសដ៏ពិសេសនេះ ក្នុងនាមស្ថាបនិកនៃទិវាកាន់ទុក្ខជាតិខ្មែរជាប្រវត្តិសាស្ត្រ ខ្ញុំព្រះករុណាខ្ញុំមានមោទនភាពនិងប្រកបដោយសេចក្តីសង្ឃឹមយ៉ាងក្រៃលែងនៅពេលដែលបានឃើញព្រះករុណាគ្រប់ព្រះអង្គ បងប្អូនរួមឈាមខ្មែរទាំងអស់ រួបរួមសាមគ្គីគ្នា រៀបចំប្រារព្ធទិវាកាន់ទុក្ខជាតិខ្មែរនៅតាមវត្តអារាម

និងទីកន្លែងនានាទូទាំងពិភពលោកជារៀងរាល់ឆ្នាំ។ សកម្មភាពនេះជាការស្តែងចេញនូវឆន្ទៈដ៏មុះមុតប្រាប់ដល់ពិភពលោកថា ព្រះសង្ឃ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមមានការឈឺចាប់យ៉ាងខ្លាំង ហើយប្រាថ្នាចង់រស់នៅដោយឯករាជ្យ សន្តិភាព សេរីភាព និងសុភមង្គល ដូចប្រជាជាតិនានាលើសកលលោកដែរ។

ឆ្លៀតឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងនូវអំណរព្រះគុណ និងអំណរគុណជាអនេកប្បការចំពោះព្រះករុណាគ្រប់ព្រះអង្គ បងប្អូនរួមឈាមខ្មែរទាំងអស់ ដែលបានបំពេញតួនាទីដ៏មានសារៈសំខាន់ និងទទួលខុសត្រូវខ្ពស់ដល់វាសនាជាតិរបស់យើង។ សូមឲ្យការឈឺចាប់ទាំងអស់ប្រែក្លាយទៅជាកម្លាំងចលករដ៏មហិមាមួយ ជំរុញចលនាតស៊ូនៃសហគមន៍ខ្មែរកម្ពុជាក្រោមឲ្យដល់គោលដៅនៃការជួយស្រោចស្រង់ប្រជាជាតិ និងមាតុភូមិខ្មែរកម្ពុជាក្រោមឲ្យខាងតែបាន។

ផ្តើមចេញពីខ្លឹមសារនៃច្បាប់ដ៏ទុយ៌ស ដែលរដ្ឋាភិបាលសាធារណរដ្ឋបារាំងបានប្រកាសឲ្យប្រើក្នុងការកាត់ទឹកដីខ្មែរកម្ពុជាក្រោមឲ្យយួននៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ សហគមន៍ខ្មែរកម្ពុជាក្រោម បានកំណត់យកថ្ងៃទី០៤ ខែមិថុនា ជាទិវាកាន់ទុក្ខរបស់ជាតិខ្មែរ និងធ្វើបុណ្យរាប់បាត្រព្រះសង្ឃ ១៩៤៩អង្គជារៀងរាល់ឆ្នាំ។ ពិព្រោះច្បាប់ដ៏អាក្រក់នេះ បានកាត់ទឹកដីខ្មែរឲ្យយួនដោយគ្មានសួរមតិពីប្រជារាស្ត្រខ្មែ ដែលជាម្ចាស់ប្រទេសឡើយ ហើយបាននាំមកនៅសេចក្តីទុក្ខវេទនារាប់មិនអស់មកឲ្យប្រជារាស្ត្រខ្មែរកម្ពុជាក្រោម និងធ្វើអោយប្រជារាស្ត្រខ្មែរកម្ពុជាក្រោមក្លាយជាជនជាតិភាគតិចនៅលើទឹកដីកំណើតរបស់ខ្លួន។

គោលបំណងនៃការកំណត់យកថ្ងៃទី០៤ មិថុនា ជាទិវាកាន់ទុក្ខរបស់ជាតិខ្មែរនោះគឺ៖

ទី១-ដើម្បីឲ្យកូនខ្មែរគ្រប់រូបចងចាំនូវព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សែនឈឺចាប់និងប្រុងប្រយ័ត្នកុំឲ្យជានប្រវត្តិសាស្ត្រដ៏អាក្រក់នេះវិលមករកខ្មែរជាថ្មីទៀត។

ទី២-ដើម្បីសំដែងនូវកតញ្ញូតាធម៌ ចំពោះព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធបុព្វបុរសខ្មែរស្នេហាជាតិ ដែលបានតស៊ូពលីជីវិតគ្មានស្តាយស្រណោះ ក្នុងបុព្វហេតុជាតិ មាតុភូមិ។

ខាងក្រោមនេះ ខ្ញុំព្រះករុណាខ្ញុំ សូមលើកយកអត្ថបទច្បាប់ ដែលអាណានិគមបារាំងបានធ្វើឡើងសម្រាប់កាត់ទឹកដីខ្មែរ (កម្ពុជាក្រោម) ឲ្យអាណានិគមវៀតណាមត្រួតត្រាបន្តរហូតសព្វថ្ងៃទាំងស្រុង មកប្រគេន និង ជម្រាបជូនដូចតទៅនេះ៖

Loi N° 49-733 du 4 Juin 1949 modifieant le statut de la Cochinchine dans l'Union française.
Après avis de l'Assemblée nationale de l'Union française, L'Assemblée nationale et le Conseil de la République ont délibéré, L'Assemblée nationale a adopté, Le Président de la République promulgue le loi don't la teneur suit:

Art. 1er – Dans le cadre fixé à L'article 60 le la Constitution de la Républicque francaise et après l'avis émis, dans sa séance du 23 april 1949, par l'Assemblée territoriale de Cochinchine, le statut de la Cochinchine est modifié dans les conditions prévues á l'article ci-aprés.

Atr. 2.- Le territoire de la Cochinchine est rattaché à l'Etat associé du Viet-Nam suivant les termes de la declaration commune du 5 juin 1948 et de la declaration du Gouvernement française du 19 août 1948. La Cochinchine cesse en conséquesnce d'avoir le statut de teritoire d'outre-mer.

Art. 3- En cas de changement du statut du Viet-Nam, le statut de la Cochinchine fera l'objet d'une nouvelle deliberation des assemblées prévues à l'article 75 de la Constitution (Titre VIII: De l'Union française).

La présente loi sera execute comme loi de l'Etat.

Fait à Toulon, le 4 Juin 1949

| **VINCENT AURIOL**<br>1er le Président de la République: | **HENRI QUEUILLE**<br>Le président du conseil des ministres, | **PAUL COSTE-FLORET**<br>Le Ministère de la France d’outre-mèr, |
|---|---|---|

*Unofficial translation [Original text in French]*

French Act No. 49-733 the June 4, 1949 amendment of the status of Cochin China in the French Union. After the opinion of the National Assembly of the French Union expressed, the National Assembly and the Council of the Republic have deliberated, the National Assembly has adopted, the President of the Republic promulgates the law as follows:

Article 1. In the framework established in Article 60 the Constitution of the French Republic and after the opinions expressed, in its meeting of April 23, 1949, by the territorial assembly of Cochin China, the statute of Cochin China is modified under the conditions laid down in article below.

Article 2. The territory of Cochin China is attached to Vietnam according to the terms of the joint declaration on June 5, 1948 and of the French declaration of the Government of August 19, 1948. Cochin China ceased to be the overseas territory of France.

Article 3. In the event of an amendment in the Constitution of Vietnam, the Constitution of Cochin China will be re-examined as stipulated in Article 75 of the Constitution (Title VIII of the French Union).

This law will be implemented as law of the State.

Toulon, June 4, 1949

| Vincent Auriol<br>The President of the French Republic | Henri Queuille<br>Chairman of the Council of Ministers | Paul Coste-Floret<br>Minister of French Overseas |
|---|---|---|

ប្រែជាភាសាខ្មែរក្រៅផ្លូវការថា ច្បាប់លេខ៤៩-៧៣៣ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩

យោងមតិរដ្ឋសភានៃសហភាពបារាំង រដ្ឋសភានិងក្រុមប្រឹក្សានៃសាធារណរដ្ឋបារាំងបានសម្រេច។

រដ្ឋសភានៃសាធារណរដ្ឋបារាំងបានអនុម័ត

ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ប្រកាសឲ្យប្រើច្បាប់ដូចតទៅ

**ប្រការ១**-អនុលោមតាមមាត្រា៦០ នៃរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋបារាំងនិងតាមមតិសភា កូសាំងស៊ីន នាសម័យប្រជុំថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៤៩ លក្ខន្តិកៈនៃទឹកដីកូសាំងស៊ីន ត្រូវបានកែប្រែតាមមាត្រាដូចមានចែងខាងក្រោម។

**មាត្រា២**-យោងតាមសេចក្តីប្រកាសរួមថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៤៨ និងសេចក្តីប្រកាសរបស់រដ្ឋាភិបាលសាធារណរដ្ឋបារាំង ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៤៨ ទឹកដីកូសាំងស៊ីន ត្រូវបានភ្ជាប់ទៅជារដ្ឋចំណុះវៀតណាម។ ទឹកដីកូសាំងស៊ីន ឈប់ស្ថិតនៅក្នុងលក្ខន្តិកៈជាទឹកដីរបស់បារាំងនៅឯនាយសមុទ្រទៀតហើយ។

**មាត្រ៣**-ក្នុងករណីលក្ខន្តិកៈប្រទេសវៀតណាមត្រូវកែប្រែ លក្ខន្តិកៈទឹកដី កូសាំងស៊ីន ត្រូវទុកជាកម្មវត្ថុ នៃការសើរើឡើងវិញ ដូចមានចែងក្នុងមាត្រា៧៥ ជំពូក VIII នៃរដ្ឋធម្មនុញ្ញសហភាពបារាំង។

ច្បាប់នេះ ត្រូវប្រកាសឲ្យប្រើដូចជាច្បាប់រដ្ឋ។

*ធ្វើនៅទូឡុង, ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩*

ហត្ថលេខា

| វាំងសង់ អូរីយ៉ូល | ហង់រី កើយ | ប៉ូល កូស្ត ផ្លរេត |
|---|---|---|
| ប្រធានាធិបតី | នាយករដ្ឋមន្ត្រី | រដ្ឋមន្ត្រីទឹកដីបារាំងឯនាយសមុទ្រ |

*បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ !*
*គណៈអធិបតីជាទីគោរព !*
*ភ្ញៀវកិត្តិយសទាំងអស់ជាទីរាប់អាន !*
*បងប្អូនរួមឈាមជាទីជាទីស្នេហា !*

កម្ពុជាក្រោមមានផ្ទៃដី ៦៨,៩៦៥គីឡូម៉ែត្រក្រឡា បច្ចុប្បន្នមានប្រជារាស្ត្រខ្មែររស់នៅជាង ១៣ លាននាក់។ មានវត្តព្រះពុទ្ធសាសនាចំនួន ៥៦៧វត្ត មានព្រះសង្ឃខ្មែរគង់នៅជាង ២០,០០០អង្គ ជាទឹកដីរួមរបស់ព្រះរាជាណាចក្រកម្ពុជា។ ទឹកដីកម្ពុជាក្រោម កាលពីសម័យដើមមានឈ្មោះថា ហ្វូណន ឬចេនឡាក្រោម។ ស្ថិតនៅខាងកើតឆៀងខាងត្បូងនៃព្រះរាជាណាចក្រកម្ពុជា។

តាមឯកសារប្រវត្តិសាស្ត្រនៃពង្សាវតាខ្មែរបានសរសេរថា ព្រះមហាក្សត្រខ្មែរព្រះនាម ***ព្រះនាងលីវយី*** ឬ ***សោមា*** ជាបឋមក្សត្រខ្មែរបានឡើងសោយរាជ្យគ្រប់គ្រងទឹកដីកម្ពុជាក្រោមដំបូងបង្អស់។ ទឹកដីកម្ពុជាក្រោមកាលពីសម័យនោះមានឈ្មោះថា ***នគរហ្វូណន*** ។ ការសោយរាជ្យសម្បត្តិនៃរាជវង្សខ្មែរបានបន្តនៅលើទឹកដីកម្ពុជាក្រោមរហូតដល់ឆ្នាំ៥៥០នៃគ្រិស្តសករាជ ទើបមានការបង្រួបបង្រួមដ៏ធំមួយនៃរាជាណាចក្រ***ហ្វូណន*** និង***ចេនឡាលើ*** (ចេនឡាដីគោគ) ទៅជា***ព្រះរាជាណាចក្រកម្ពុជា***។ ស្ថាបនិកដ៏ឆ្នើមនៃការបង្រួបបង្រួមបង្កើតបានទៅជា***ព្រះរាជាណាចក្រកម្ពុជា*** រហូតបច្ចុប្បន្ន ដែលអ្នកប្រវត្តិសាស្ត្រកំពូលៗបានទទួលស្គាល់នោះគឺ ***ព្រះបាទភវវរ្ម័ន*** ។

ក្រោយពីការបង្រួបបង្រួមហើយបង្កើតបានជាព្រះរាជាណាចក្រកម្ពុជាហើយនោះ បញ្ហាទំនាស់ផ្ទៃក្នុងក៏បានបន្តកើតមានជាបន្តបន្ទាប់ ប៉ុន្តែពុំបានជាឧបស័គ្គរាំងដល់ដំណើរការកសាងព្រះរាជាណាចក្រកម្ពុជាថ្មីនេះឡើយ។ ក្រោមព្រះរាជកិច្ចដឹកនាំដ៏ឆ្លៀសវៃនៃព្រះមហាក្សត្រខ្មែរ ជាពិសេស នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាក្លាយទៅជាមហាអាណាចក្រមួយដ៏ធំល្បីរន្ទឺនៅលើសកលលោក។

នៅឆ្នាំ១៦២៣នៃគ្រិស្តសករាជ ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ ទើបឃើញវត្តមានជនជាតិយួនដំបូងបង្អស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គឺតាមរយៈរាជាភិសេកព្រះបាទជ័យជេដ្ឋាទី ២ជាមួយបុត្រីនៃរាជវង្សយួន។ ចាប់ពីពេលនោះមក ពួកនិគមជនយួនបានចាប់ផ្តើមចូលមកតាំងទីលំនៅនៅលើទឹកដីខ្មែរជាបន្តបន្ទាប់ ដោយគ្មានកោតក្រែងពលរដ្ឋខ្មែរជាម្ចាស់ស្រុកឡើយ។ ក្រោយពីព្រះបាទជ័យជេដ្ឋាទី២ បានសោយទីវង្គត បញ្ហានិគមជនយួននៅក្នុងទឹកដីខ្មែរបានក្លាយជាប្រធានបទមួយដ៏ស្មុគ្រស្មាញស្រាយមិនរួច រហូតឈានដល់ការបាត់បង់ទឹកដីខ្មែរដ៏ធំធេង គឺទឹកដីកម្ពុជាក្រោមទាំងស្រុង។ ជាអកុសល នៅពេលដែលប្រជារាស្ត្រខ្មែរកំពុងជាប់ដៃប្រយុទ្ធតតាំងបណ្តេញយួនចេញពីស្រុក ស្រាប់តែលេចមុខអាណានិគមបារាំងបានចូលមកវាយយកទឹកដីកម្ពុជាក្រោមធ្វើជាទឹកដីរបស់ខ្លួននៅឯនាយសមុទ្រទៅវិញ។ មិនតែប៉ុណ្ណោះ ដោយអំណាចអាណានិគមរបស់ខ្លួន បារាំងបានធ្វើច្បាប់ដ៏ទុយ៉សមួយកាត់ទឹកដីខ្មែរឲ្យយួននៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ រហូតសព្វថ្ងៃ ដោយមិនបានសួរមតិពីថ្នាក់ដឹកនាំ ឬប្រជារាស្ត្រខ្មែរ ដែលជាម្ចាស់ប្រទេសទាល់តែសោះ។

បន្ទាប់ពីទទួលយកការត្រួតត្រាបន្តពីអាណានិគមបាំងនៅលើទឹកដីកម្ពុជាក្រោមទាំងស្រុងរួចមក យួនបានចាប់ផ្តើមអនុវត្តន៍នយោបាយរំលាយពូជសាសន៍ខ្មែរយ៉ាងឃោរឃៅព្រៃផ្សៃជាទីបំផុត។ វត្តអារាមមួយចំនួនត្រូវបំផ្លាញចោលទាំងស្រុង ព្រះសង្ឃខ្មែរត្រូវបង្ខំឲ្យកោរសក់ទុកចិញ្ចើម ពាក់អាវដៃធំពិណាឈាម

ជ្រូក សូត្រធម៌គោះត្រដោក ដូចព្រះសង្ឃយួន។ ហាមឃាត់ប្រជារាស្ត្រខ្មែរមិនឲ្យនិយាយភាសាខ្មែរ។ ចាប់ប្រជាពលរដ្ឋខ្មែរកប់ទាំងរស់ធ្វើជាមុមចង្រានដាំតែអុង(ដាំតែឲ្យលោកធំយួន) ដុតខ្មែរទាំងរស់ជាដើម។

ពីសម័យមួយទៅសម័យមួយ ពីរបបមួយទៅរបបមួយអាណានិគមយួនបានប្រើប្រាស់គ្រប់រូបភាពក្នុងការរំលាយពូជសាសន៍ខ្មែរកម្ពុជាក្រោមជានិច្ច ព្រោះយួនបានគិតថា ថ្ងៃណាមួយខ្មែរក្រោមនិងខ្មែរកណ្ដាលរួបរួមគ្នា និងទាមទារទឹកដីកម្ពុជាក្រោមមកវិញជាក់ជាមិនខាន។ ដូចនេះ យួនត្រូវតែអនុវត្តយុទ្ធសាស្ត្របំបែកបំបាក់ដើម្បីត្រួតត្រា។

ដូច្នេះ សកម្មភាពនៃអាណានិគមវៀតណាមបច្ចុប្បន្នបានធ្វើឲ្យយើងមានការព្រួយបារម្ភយ៉ាងខ្លាំងជាងពេលណាៗទាំងអស់ចំពោះការបាត់បង់ពូជសាសន៍ខ្មែរនៅកម្ពុជាក្រោម។ ដោយសារថា សកម្មភាពរបស់អាជ្ញាធរយួនសព្វថ្ងៃបានស្តែងចេញហាក់ដូចជាបានក្តោបក្តាប់ត្រួតត្រាកម្ពុជាទាំងស្រុង ហើយបាននិងកំពុងកាត់ផ្តាច់ការទាក់ទងរវាងខ្មែរក្រោមនិងខ្មែរកណ្តាលយ៉ាងពិតប្រាកដ។

ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ អាណានិគមយួនបានផ្លាស់ប្តូររបបត្រួតត្រាថ្មីនៅលើទឹកដីខ្មែរកម្ពុជាក្រោមរហូតបច្ចុប្បន្ន គឺរបបសាធារណរដ្ឋសង្គមនិយមវៀតណាម។ របបអាណានិគមយួនថ្មីនេះមិនបានបន្ធូរបន្ថយក្នុងការអនុវត្តន៍យោបាយបំបាត់ពូជសាសន៍ខ្មែរកម្ពុជាក្រោមនោះទេ។ ជាក់ស្តែងនៅចុងឆ្នាំ១៩៧៥ យួនបានចាប់មេដឹកនាំនិងរំលាយចោលទាំងស្រុងនូវពុទ្ធិកសមាគមសហព័ន្ធសិស្ស ដែលដឹកនាំដោយលោក ចន្ទ័ ជាភិរម្យ។ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ យួនបានបង្ក្រាបនិងសម្លាប់យ៉ាងឃោរឃៅទៅលើប្រជារាស្ត្រខ្មែរស្លូតត្រង់ ដែលទាមទារសិទ្ធិសេរីភាពរបស់ខ្លួន ព្រមទាំងចាប់ដាក់ពន្ធនាគារ និងធ្វើទារុណកម្មគ្មានត្រាប្រណី។ ក្នុងនោះស្លាប់ ៦៥នាក់ រងរបួសធ្ងន់ស្រាលជាង ៥០០នាក់ ចាប់ដាក់ពន្ធនាគារនិងធ្វើទារុណកម្មជាង ៨០០០នាក់។ កាត់ទោសប្រហារជីវិត ៣នាក់ គឺលោក ថាច់ គឹន លោក គឹម វី និងលោក ថាច់ ដៀក។ ជាប់គុកមួយជីវិតឆ្នាំ ៦នាក់ ២០ឆ្នាំ ៩នាក់ ១៥ឆ្នាំ ៩នាក់ ១៣ឆ្នាំ ៥នាក់ និង ៣ឆ្នាំម្នាក់។

ទំនាក់ទំនងរវាងខ្មែរក្រោមនិងខ្មែរកណ្តាលជាជនរួមឈាមតែមួយ ដែលធ្លាប់មានជាប្រពៃណីតាំងពីការកកើតទឹកដីខ្មែររហូតមកត្រូវបានកាត់ផ្តាច់ទាំងស្រុង។ ដូចជាស្ថាប័នព្រះសង្ឃព្រះពុទ្ធសាសនាពុំបានស្ថិតនៅក្រោមការដឹកនាំរបស់ស្ថាប័នសង្ឃព្រះពុទ្ធសាសនានៅកម្ពុជាដូចពីមុនឡើយ គឺត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់បក្សកុម្មុយនិស្តវៀតណាម។ ពុទ្ធសាសនបណ្ឌិត្យរងនៅកម្ពុជាក្រោម (ទីស្នាក់ការនៅខេត្តឃ្លាំង) ត្រូវបិទចោល។ល។ និង ។ល។

ឆ្នាំ១៩៨៤ ដល់ ឆ្នាំ១៩៨៧ យួនបានចាប់មេដឹកនាំសំខាន់ៗនៃចលនាព្រះសង្ឃសាមគ្គីស្នេហាជាតិ សាស្ត្រាចារ្យ ព្រះធម្មាចារ្យ ព្រះឧទ្ទេសាចារ្យ ព្រះឧបជ្ឈាយ៍ គ្រូបង្រៀននិងអ្នកប្រាជ្ញបញ្ញវន្តខ្មែរចំនួន៤២៤៨រូបដាក់ពន្ធនាគារ និង ធ្វើទារុណកម្មយ៉ាងអមនុស្សធម៌ជាទីបំផុត។ ក្នុងនោះមានព្រះតេជគុណ គឹម សាង ព្រះសង្ឃនាយកនៅកម្ពុជាក្រោម ព្រះតេជគុណគឹម តុក ចើង ព្រះមេគណខេត្តព្រះត្រពាំង និងជាប្រធានសមាគមព្រះសង្ឃសាមគ្គីស្នេហាជាតិ ត្រូវបានយួនធ្វើទារុណកម្ម និង ចាក់ថ្នាំធ្វើគតនៅក្នុងពន្ធនាគារ។ បណ្ឌិតាចារ្យ ហាញ់ សុវណ្ណ ប្រធានស្ថាបនិកនៃពុទ្ធិកសិក្សាធម្មវិន័យ ត្រូវធ្វើទារុណកម្មបង្អត់បាយរហូតដល់ស្លាប់នៅពន្ធនាគារ។ល។ និង ។ល។

ចាប់ពីឆ្នាំ១៩៨៥រហូតមកបច្ចុប្បន្ន សាលារៀនភាសាខ្មែរគ្រប់កម្រិតសិក្សា ដែលបានរៀបចំដោយគណៈចលនាព្រះសង្ឃសាមគ្គីស្នេហាជាតិបន្តតាំងពីបុរាណរៀងមកនោះ ត្រូវបានអាជ្ញាធរអាណានិគមវៀតណាមបិទចោលទាំងស្រុង ហើយបានបង្ខំឲ្យព្រះសង្ឃខ្មែរទទួលយកការសិក្សារៀនសូត្រតាមបែបថ្មីដែលរៀបចំនិងត្រួតពិនិត្យយ៉ាងម៉ត់ចត់ដោយអាជ្ញាធរអាណានិគមវៀតណាមវិញ។ កម្មវិធីសិក្សា ដែល

បានរៀចំដោយអាជ្ញាធរអាណានិគមវៀតណាមនោះគ្រាន់តែសំរាប់អានបានសរសេរបាន គឺពុំមានគុណភាពអ្វីឡើយ ជាពិសេស សំរាប់បំពាក់គោលជំហរបក្សកុម្មុយនិស្តវៀតណាម និងធ្វើឲ្យខ្មែរនិងខ្មែរស្អប់គ្នាបែកបាក់គ្នាតែប៉ុណ្ណោះ។

រីឯ ព្រះសង្ឃពុទ្ធសាសនាខ្មែរវិញ ត្រូវបានអាជ្ញាធរអាណានិគមវៀតណាម បង្ខំឲ្យធ្វើស្រែចម្ការនិងចិញ្ចឹមសត្វពាហនៈដូចគ្រហស្ថ ដែលជានយោបាយដ៏ទុច្ចរិតមួយ ដើម្បីធ្វើឲ្យប្រជារាស្ត្រខ្មែរបាត់បង់ជំនឿមកលើព្រះពុទ្ធសាសនា ដែលជាគ្រឹះនិងជាព្រលឹងនៃប្រជាជាតិខ្មែរនៅកម្ពុជាក្រោម។ ហាមឃាត់ដាច់ខាតមិនឲ្យមានការបង្កើតអង្គការសមាគមក្រៅរដ្ឋាភិបាលឡើយ។ ការដើរប្រមូលយកវត្ថុបូរាណខ្មែរតាមវត្តនានាក្នុងលេសដើម្បីយកមករក្សាទុកកន្លែងសុវត្ថិភាព។ ទំនៀមទម្លាប់ខ្មែរមួយចំនួនត្រូវហាមឃាត់ ដូចជាទំនៀមទម្លាប់បង្ហោះគោមក្នុងពិធីបុណ្យអុំទូក អកអំបុក និងសំពះព្រះខែ។ ហាមដាច់ខាតមិនឲ្យស្តាប់វិទ្យុនិងមើលទូរទស្សន៍ខ្មែរ ដែលផ្សាយចេញពីប្រទេសកម្ពុជា មិនឲ្យស្តាប់វិទ្យុអាស៊ីសេរី វិទ្យុសម្លេងសហរដ្ឋអាមេរិក និងប្រើប្រាស់ប្រព័ន្ធ Internet ជាដើម។ សំឡុតគំរាមមិនឲ្យព្រះសង្ឃនិងប្រជារាស្ត្រខ្មែរទាក់ទងជាមួយសហគមន៍ខ្មែរកម្ពុជាក្រោមនៅខាងក្រៅជាដាច់ខាត។ ករណីនេះ បាននិងកំពុងចាប់ផ្សឹកព្រះសង្ឃនិងចាប់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមដាក់គុកជាបន្តបន្ទាប់ ដោយបានចោទប្រកាន់ថា បានទាក់ទងជាមួយសហគមន៍ខ្មែរកម្ពុជាក្រោមនៅបរទេស។ ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ដែលចេញមុខតវ៉ារឿងដីធ្លីត្រូវចាប់ខ្លួនដាក់ពន្ធនាការ ដូចករណីលោក ចៅ ហេន នៅខេត្តមាត់ជ្រូក សូម្បីតែធ្លាក់ខ្លួនឈឺធ្ងន់ដើរលែងរួចក៏អាជ្ញាធរអាណានិគមវៀតណាម មិនអនុញ្ញាតឲ្យនាំចេញពីពន្ធនាគារទៅព្យាបាលដែរ។ នេះជាអំពើអមនុស្សធម៌ និងរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ មិនអាចទទួលយកបានឡើយ។

ភាពក្រីក្របានបង្ខំចិត្តឲ្យប្រជាពលរដ្ឋខ្មែរ ចាកចោលភូមិឋានទៅធ្វើកម្មករស៊ីឈ្នួលយួនស្ទើរស្ងាត់ស្រុក ដែលជាយុទ្ធសាស្ត្ររំលាយពូជសាសន៍ខ្មែរយ៉ាងត្រជាក់ និងងាយស្រួលជាទីបំផុត។ ម្យ៉ាងទៀតព្រះសង្ឃនិងប្រជាពលរដ្ឋខ្មែរ ដែលបាននិមន្តនិងធ្វើដំណើរទៅលេងស្រុកកំណើត ឬទៅសួរសុខទុកសាច់ញាតិនៅលើទឹកដីកម្ពុជាក្រោមតែងតែជួបការគំរាមកំហែងតាមគ្រប់រូបភាព ដូចជាការកោះហៅឲ្យបង្ហាញខ្លួននៅសាលាឃុំ សាលាស្រុក សាលាខេត្ត ដើម្បីសួរចម្លើយអំពីសកម្មភាពផ្សេងៗ និងដកហូតលិខិតឆ្លងដែនបង្ខាំងទុក ទោះបីជាមិនមានកំហុសអ្វីក៏ដោយ។

សកម្មភាពរបស់អាណានិគមវៀតណាមបច្ចុប្បន្ន បានបង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីនយោបាយទុច្ចរិតក្នុងការរំលាយពូជសាសន៍ខ្មែរនៅកម្ពុជាក្រោមដ៏ពិតប្រាកដ មិនអាចប្រកែកបាន។ ពីព្រោះអាណានិគមវៀតណាមបាននិងកំពុង ៖

១-ធ្វើឲ្យប្រជារាស្ត្រខ្មែរកម្ពុជាក្រោមបោះបង់ចោលការបួសរៀនរហូតដល់បាត់បង់ការសិក្សារៀនសូត្រភាសាខ្មែរ និងធ្វើឲ្យប្រជារាស្ត្រខ្មែរបាត់បង់ជំនឿទៅលើព្រះពុទ្ធសាសនា ដែលជាមូលដ្ឋានគ្រឹះនៃព្រលឹងពូជសាសន៍ខ្មែរនៅកម្ពុជាក្រោម។

២-ប្តូរសញ្ជាតិខ្មែរឲ្យទៅជាយួន ដោយមិនបានសួរសាមីខ្លួន (ប្តូរពីសញ្ជាតិខ្មែរទៅជាសញ្ជាតិគិញ)។

៣-មិនបង្កើតរោងចក្រ ឬ សិប្បកម្ម (បង្កើតការងារ) នៅតំបន់ប្រជាពលរដ្ឋខ្មែររស់នៅ។

៤-ភាពក្រីក្របង្ខំចិត្តទៅស៊ីឈ្នួលយួននៅគ្រប់ទីកន្លែង ដែលជាការងាយរំលាយពូជសាសន៍ខ្មែរជាទីបំផុត។ ព្រោះ ទី១-មិនអាចនិយាយភាសាខ្មែរបាន។ ទី២-ងាយក្នុងការទទួលឥទ្ធិពលវប្បធម៌យួនជ ទី៣-អាចសម្ពន្ធភាពប្តីឬប្រពន្ធជាមួយជនជាតិយួន។ ចំណុចនេះគឺជាការ

រំលាយពូជសាសន៍ខ្មែរឲ្យទៅជាយួនយ៉ាងស្របច្បាប់បំផុត។
៥-សម្លុតគំរាមកំហែងបំបាក់ស្មារតី កុំឲ្យហ៊ានងើបឡើងតស៊ូ។

៦៣ឆ្នាំបានកន្លងផុតក្រោមនឹមត្រួតត្រារបស់អាណានិគមយួន ព្រះសង្ឃនិងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមបានរស់នៅឆ្លងកាត់មហាសមុទ្រទុក្ខយ៉ាងសែនវេទនាជាទីបំផុត។ ប៉ុន្តែទង្វើដ៏ឃោរឃៅព្រៃផ្សៃទាំងនោះពុំបានធ្វើឲ្យព្រះសង្ឃនិងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមបញ្ឈប់ការតស៊ូ ដើម្បីការពារពូជសាសន៍របស់ខ្លួនឡើយ។ ផ្ទុយមកវិញ រិតតែបង្កើនកម្លាំងតស៊ូទ្វេដង មិនលុតជង្គង់ចំពោះមុខសត្រូវជាដាច់ខាត់ ហើយនៅតែចាត់ទុកថា ទឹកដីកម្ពុជាក្រោម ជាទឹកដីរបស់ខ្មែរ អាណានិគមបារាំងកាត់ទឹកដីខ្មែរឲ្យយួន គឺជាទង្វើខុសច្បាប់ជារៀងដរាប។

កាលណានិយាយពីការតស៊ូ យើងមិនត្រូវបំភ្លេចមហាវីរបុសខ្មែរដែនដីសណ្តទន្លេមេគង្គ (កម្ពុជាក្រោម) នៅសតវត្សរ៍ទី១៩បានទេ គឺឧកញ៉ាសឺន គុយ ដែលហ៊ានលះបង់ជីវិតឲ្យយួនកាត់កទាំងរស់ជាថ្នូរនឹងការរក្សាទុកពូជសាសន៍ សាសនា ទំនៀមទម្លាប់ខ្មែរនៅកម្ពុជាក្រោម។ ព្រះមហាវីរក្សត្រព្រះបាទអង្គឌួង បានដឹកនាំទ័ពដោយផ្ទាល់ព្រះអង្គទៅវាយដណ្តើមយកកម្ពុជាក្រោមមកវិញ។ល។

នៅសតវត្សរ៍ទី២០ មានវីរបុរស ថាច់ គឹន គឹម រី និងថាច់ ដៀក ត្រូវបានអាជ្ញាធរអាណានិគមយួនកាត់ទោសប្រហារជីវិត ដោយសារតែបានដឹកនាំប្រជារាស្ត្រខ្មែរតស៊ូទាមទារសិទ្ធិសេរីភាពនៅឆ្នាំ១៩៧៦។ ព្រះមហាវីរសមណៈ គឹម តុកចើង ត្រូវបានអាជ្ញាធរអាណាយួនចាក់ថ្នាំធ្វើគតនៅក្នុងពន្ធនាគារឆ្នាំ១៩៨៧ ដោយសារតែព្រះអង្គដឹកនាំចលនាព្រះសង្ឃ និងប្រជារាស្ត្រខ្មែរឲ្យសិក្សារៀនសូត្រអក្សរសាស្ត្រខ្មែរ និងការពារនូវទំនៀមទម្លាប់វប្បធម៌ខ្មែរ។ល។ នេះគ្រាន់តែជាការលើកយកមកឧទាហរណ៍តែប៉ុណ្ណោះនៅមានព្រះវីរសមណៈ ព្រះវីរព្រះហាក្សត្រ វីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារីជាច្រើនរូបផ្សេងទៀត។

នៅក្នុងរជ្ជកាលព្រះករុណាព្រះមហាវីរក្សត្រព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះអង្គបានតស៊ូយ៉ាងស្វិតស្វាញ ដើម្បីបញ្ជាក់ឲ្យសហគមន៍អន្តរជាតិបានដឹងអំពីសិទ្ធិស្របច្បាប់របស់កម្ពុជានៅលើទឹកដីកម្ពុជាក្រោម។ នៅក្នុងព្រះរាជសារ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៤៥ ព្រះអង្គបានបញ្ជាក់ប្រាប់អធិរាជជប៉ុនយ៉ាងច្បាស់អំពីសិទ្ធិរបស់កម្ពុជានៅលើដែនដីកម្ពុជាក្រោម។ ព្រះរាជសារ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៤៨ បានប្រឆាំងយ៉ាងដាច់ខាតចំពោះសំណើរបស់អធិរាជបាវដាយ ដែលបានស្នើសុំបារាំងបង្រួបបង្រួមទឹកដីតែមួយដែលភាសាយួនហៅថា Ky ទាំង ៣ គឺ Trung Ky Nam Ky Bắc Ky ។ មានន័យថាយួនចង់យកទឹកដីចាម (Trung Ky) ទឹកដីកម្ពុជាក្រោម (Nam Ky) មករួមជាមួយទឹកដីវៀតណាមតែមួយ។

ព្រះរាជសារចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៥ ព្រះមហាវីរក្សត្រព្រះបាទសម្តេចព្រះ នរោត្តម សីហនុ បានឡាយជាអាទ៍ថា ការកាត់ទឹកដីខ្មែរកម្ពុជាក្រោមឲ្យវៀតណាម នៅឆ្នាំ១៩៤៩នោះ ជាការខុសច្បាប់ និងអយុត្តិធម៌បំផុត។ យ៉ាងហោចណាស់ក៏អាណានិគមបារាំងត្រូវប្រគល់ទឹកដីកម្ពុជាក្រោម ៥០ភាគរយមកឲ្យព្រះរាជាណាចក្រកម្ពុជាដែរ។

ការស្រង់ដោយសង្ខេបយកមកជាឧទាហរណ៍នេះ គឺជាសក្ខីយកម្មបញ្ជាក់យ៉ាងច្បាស់ថា ទាំងព្រះមហាក្សត្រខ្មែរគ្រប់ជំនាន់ ទាំងប្រជារាស្ត្រខ្មែរម្ចាស់ទឹកដី ទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយក៏ពុំដែលបានបោះបង់ទឹកដីកម្ពុជាក្រោមចោលម្តងណាឡើយ។

*បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ !*
*គណៈអធិបតីជាទីគោរព !*
*បងប្អូនរួមឈាមជាទីស្នេហា !*

ឆ្លៀតក្នុងឱកាសដ៏វិសេសថ្លៃថ្លានេះ ខ្ញុំព្រះករុណាខ្ញុំ សូមគោរពអំពាវនាវព្រះករុណាគ្រប់ព្រះអង្គ និងបងប្អូនរួមឈាមទាំងអស់ ព្រះមេត្តានិងមេត្តារួបរួមសាមគ្គីគ្នាជាធ្លុងមួយ ក្នុងនាមជាបងប្អូនរួមឈាមខ្មែរ ក្នុងមហាគ្រួសារខ្មែរតែមួយ ដើម្បីបន្តវេននៃការតស៊ូពីបុព្វបុរសរបស់យើង ក្នុងការការពារពូជសាសន៍ សាសនា ទំនៀមទម្លាប់ វប្បធម៌ អក្សរសាស្ត្រ និងប្រពៃណីជាតិខ្មែរ នៅកម្ពុជាក្រោមឲ្យខាងតែបាន។ បែកសាមគ្គីគឺស្លាប់ រួមសាមគ្គីគឺរស់។ បើយើងមិនអាចទាមទារនូវអ្វីដែលបានបាត់បង់មកវិញទេ យើងត្រូវរក្សាអោយបាននូវអ្វី ដែលបុព្វបុរសរបស់យើងបានបន្សល់ទុកឲ្យយើង។ បើមិនដូច្នោះទេ មានន័យថា យើងជាខ្មែរជំនាន់ក្រោយពិតជាអកតញ្ញូចំពោះបុព្វបុរសរបស់ខ្លួន មិនសមនិងរស់លើផែនដីនេះទេ។

ដើម្បីឲ្យកូនខ្មែរគ្រប់រូបចងចាំ និងជៀសវាងកុំឲ្យដានប្រវត្តិសាស្ត្រនូវដ៏សែនឈឺចាប់នៃការបាត់បង់ទឹកដីវិលមកសារជាថ្មី និងសំដែងនូវកតញ្ញូតាធម៌ ចំពោះវិញ្ញាណក្ខន្ធនិងព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវិញ្ញាណក្ខន្ធព្រះវីរៈព្រះមហាក្សត្រ វិញ្ញាណក្ខន្ធវីរបុរស វីរនារី ខ្មែរស្នេហាជាតិ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម សូមស្នើប្រមុខរាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា ជាថ្មីម្តងទៀត សូមមេត្តាបញ្ចូលថ្ងៃទី០៤ ខែមិថុនា ជាទិវាកាន់ទុក្ខជាតិខ្មែរជារៀងរាល់ឆ្នាំ។

តាងនាមអង្គការ-សមាគមខ្មែរកម្ពុជាក្រោម និងក្នុងនាមទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំផ្ទាល់ សូមថ្លែងអំណរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅ ប្រគេននិងជូនព្រះករុណាគ្រប់ព្រះអង្គ បងប្អូនរួមឈាមទាំងអស់ទាំងនៅឯនាយសមុទ្រ ទាំងនៅទីនេះក្តី ដែលបានជួយឧបត្ថម្ភជាសម្ភារៈ និងថវិកាដល់ការរៀបចំពិធីបុណ្យជាប្រវត្តិសាស្ត្រនេះ និងបាននិមន្តនិងអញ្ជើញមកចូលរួមយ៉ាងច្រើនកុះករជួយញ៉ាំងកម្មវិធីបុណ្យរបស់យើងទាំងអស់គ្នាមានសភាពឱឡារិកអធឹកអធ៌មនិងប្រកបដោយអត្ថន័យដ៏ជ្រាលជ្រៅ។

ដោយឥដ្ឋមនុញ្ញផលដែលកើតមានអំពីបុណ្យកតញ្ញូកតវេទិតាធម៌នាពេលនេះ ទូលព្រះបង្គំយើងខ្ញុំ សូមឧទ្ទិសកុសលទាំងនេះប្រគេនព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ថ្វាយព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាវីរក្សត្រ និងជូនវិញ្ញាណក្ខន្ធវីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារី ខ្មែរស្នេហាជាតិទាំងអស់ បានសោយសុខក្នុងសុគតិភព និងសូមឧត្តមគតិជាតិស្នេហាដ៏ពិតប្រាកដរបស់ព្រះវីរសមណៈ ព្រះវីរព្រះមហាក្សត្រ និងវីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារី ស្ថិតក្នុងស្មារតីប្រជារាស្ត្រខ្មែរគ្រប់រូប កុំបីខាន។

សូមព្រះបរមរាជានុញ្ញាត លើកព្រះរាជកុសលដ៏ថ្លៃថ្លានេះដែរ ថ្វាយព្រះករុណាព្រះមហាវីរក្សត្រ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ និងសម្តេចព្រះមហាក្សត្រីយ៍ នរោត្តម មុនានាថ សីហនុ និងព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណវាងវៃ ព្រះជន្មយឺនយូរជាងរយព្រះវស្សា ឆ្ងាយចាករោគា មារសត្រូវទាំងពួង ដើម្បីប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជានុរាស្ត្រខ្មែរនៅគ្រប់ទិទីតរៀងទៅ។

សូមប្រគេនព្រះពរព្រះករុណាគ្រប់ព្រះអង្គជាទីសក្ការៈ ថ្វាយព្រះពរសម្តេច ស៊ីសុវត្ថិ ពង្សនារី មុនីពង្ស ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសូមគោរពជូនពរ លោកជំទាវ លោក លោកស្រី បងប្អូនរួមឈាមទាំងអស់ បានប្រកបទៅដោយពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

***សូមអរព្រះគុណ និងអរគុណ !***

khmerkromngo.org